## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយស សូមគោរពជម្រាបជូន **ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ ទីប្រឹក្សា លោក លោកស្រី ប្រធានអង្គភាព និងមន្ត្រីរាជការ** ទាំងអស់មេត្តាជ្រាបថា ដោយមានកិច្ចសហការជាមួយក្រុមហ៊ុនទូរស័ព្ទ មិត្តហ្វូន (Metfone Cambodia) ក្រសួងទទួលបានកញ្ចប់សាជីវកម្ម (Corporate Package) ដែលមានលក្ខណៈពិសេស និងអត្ថប្រយោជន៍ជាច្រើនសម្រាប់មន្ត្រីរាជការទាំងអស់ ដោយគ្រាន់តែតម្រូវឱ្យធ្វើការបញ្ចូលទឹកប្រាក់ចំនួន ៣ ដុល្លារ (បីដុល្លារសហរដ្ឋអាមេរិក) ជារៀងរាល់ខែ នោះមន្ត្រីរាជការទាំងអស់នឹងទទួលបាននូវអត្ថប្រយោជន៍ដូចខាងក្រោម៖

១- មិនគិតប្រាក់ចំពោះការហៅទូរស័ព្ទចេញ (Unlimited Free call in group) នៅក្នុងក្រុមទំនាក់ទំនងក្នុងក្រសួង ឬប្រចាំអង្គភាពរបស់ខ្លួន (អាចបង្កើតជាក្រុមទំនាក់ទំនងតាមអង្គភាពបាន)

២- មិនគិតប្រាក់ចំពោះការហៅទូរស័ព្ទចេញទៅប្រព័ន្ធក្រុមហ៊ុន មិត្តហ្វូន ដូចគ្នា (ដែលមិនស្ថិតនៅក្នុងក្រុម) ចាប់ពីចន្លោះម៉ោង ៧:០០ នាទីព្រឹក រហូតដល់ម៉ោង ៦:០០ នាទីល្ងាច

៣- ធ្វើការផ្ញើសារដោយសេរីនៅក្នុងប្រព័ន្ធទូរស័ព្ទ មិត្តហ្វូន (Free SMS within Metfone network) និងអាចបង្កើតជាក្រុមផ្ញើសារតាមអង្គភាពនីមួយៗ

៤- ទទួលបានអ៊ិនធើណែតចំនួន ៥០០ មេហ្គាបាយ (Free Data 500MB) ក្នុង ១ខែៗ

៥- ក្រុមហ៊ុននិងផ្តល់លេខទូរស័ព្ទពិសេសក្បាល ០៦៧ XXABAB (ឧទាហរណ៍: ០៦៧ ៩៧ ៩៣៩៣) និង ០៦៧ XXXAAA (ឧទាហរណ៍: ០៦៧ ៩៧៦ ៧៧៧) សម្រាប់មន្ត្រីក្រសួង

៦- ចំពោះទឹកប្រាក់ដែលបានបញ្ចូលចំនួន ៣ ដុល្លារ គឺអាចប្រើប្រាស់លេងអ៊ិនធើណែត ឬអាចហៅចេញទៅកាន់ប្រព័ន្ធក្រុមហ៊ុនទូរស័ព្ទដទៃបាន ប៉ុន្តែមិនអាចធ្វើការប្តូរលុយបានទេ។

អាស្រ័យដូចបានជម្រាបជូនខាងលើប្រសិនជា **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទាំងអស់ចង់ចងជាក្រុម និងប្រើប្រាស់កញ្ចប់សេវានេះ សូមមេត្តាទំនាក់ទំនងមកកាន់នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ដោយសេចក្តីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៥ ឆ្នាំ២០១៦

<u>ព័ត៌មានបន្ថែមសូមទំនាក់ទំនង</u>

- ០១២ ៣០០ ១១៨
- ០៧៧ ៩៩៩ ៧៩៩